## ប្រធាន សេដាក វិភាគអំពីការនាំចេញអង្ករបស់ប្រទេសកម្ពុជា៖

**ភ្នំពេញ៖** នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០១១ លោកបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការសេដាក បានផ្តល់បទសំភាសន៍ វិភាគអំពីការនាំចេញអង្ករប្រទេសកម្ពុជា ជាមួយនឹងកម្មវិធីព័ត៌មានថ្ងៃត្រង់របស់បណ្តាញទូរទស្សន៍ស៊ីធីអិន។ លោកបណ្ឌិតបានសំណែងនូវសុទិដ្ឋិនិយមថា ប្រទេសកម្ពុជានឹងអាចសម្រេចនូវគោលបំណងក្នុងការនាំអង្ករចេញឱ្យបាន ១លានតោនត្រឹមឆ្នាំ ២០១៥។ លោកបណ្ឌិតក៏បានសំណូមពរដល់រដ្ឋាភិបាល ឱ្យបន្តយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗជាអាទិភាពមួយចំនួនដូចជា៖ ដើមទុន (គួរវិនិយោគឱ្យច្រើនក្នុងវិស័យកសិកម្ម និងបញ្ចុះអត្រាការប្រាក់) ប្រពន្ធ័ធារាសាស្ត្រ បច្ចេកទេសកសិកម្ម និងការអភិរក្សនូវគោត្របីរបស់កសិករជាដើម។